


# កិច្ចសន្យាការងារ

## តើអ្វីជាកិច្ចសន្យាការងារ?

កិច្ចសន្យាការងារ គឺជាកិច្ចសន្យាដែលកំណត់ពីសិទ្ធិ កាតព្វកិច្ច និងទំនាក់ទំនង រវាងកម្មករ **និយោជិត** និង**និយោជក**។ កិច្ចសន្យានេះអាចធ្វើជាលាយល័ក្ខណ៍អក្សរ ឬ ដោយមាត់ទទេ។




## ប្រភេទនៃកិច្ចសន្យាការងារ

### ១. កិច្ចសន្យាការងារដែលមានកំណត់ថិរវេលា (FDC)

- រយៈពេលមិនលើសពី ២ ឆ្នាំ។
- ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ
- មានបញ្ជាក់កាលបរិច្ឆេទផុតកំណត់ច្បាស់លាស់




### ២. កិច្ចសន្យាការងារមានថិរវេលាមិនកំណត់ (UDC)

- គ្មានរយៈពេលអតិបរមា
- មិនចាំបាច់មានទម្រង់កិច្ចសន្យាទេ (អាចធ្វើដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ)
- មិនត្រូវការកាលបរិច្ឆេទផុតកំណត់ទេ

### FDC អាចផ្លាស់ប្តូរទៅជា UDC ប្រសិនបើ៖

- FDC បានផុតកំណត់ ប៉ុន្តែការងារនៅតែបន្តដោយស្ងៀមស្ងាត់
- ប្រសិនបើកិច្ចសន្យា FDC ត្រូវបានបន្ត ហើយរយៈពេលរួមលើសពី ២ ឆ្នាំ។

## ការបញ្ចប់កិច្ចសន្យា FDC

និយោជកមានកាតព្វកិច្ចក្នុងការជូនដំណឹងដែលមានកំណត់ដូចខាងក្រោម៖

- កិច្ចសន្យា FDC លើសពី ៦ ខែ ត្រូវជូនដំណឹងជាមុន ១០ ថ្ងៃ អំពីការផុតរលត់
- កិច្ចសន្យា FDC លើសពី ១ ឆ្នាំ ត្រូវជូនដំណឹងជាមុន ១៥ ថ្ងៃ អំពីការផុតរលត់

## អត្ថប្រយោជន៍ទទួលបានក្រោយបញ្ចប់កិច្ចសន្យា FDC

- ប្រាក់ឈប់សម្រាកប្រចាំឆ្នាំដែលនៅសល់
- ប្រាក់ឈ្នួលចុងក្រោយ
- ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាស្មើនឹង ៥% នៃប្រាក់ឈ្នួលសរុបក្នុងរយៈពេលកិច្ចសន្យា។



<u>ចំណាំ៖</u> ប្រសិនជានិយោជិតបានប្រព្រឹត្តអំពើខុសធ្ងន់ធ្ងរ រឺ និយោជិតលាលែងពីតំណែងខ្លួនឯង នោះនឹងមិនទទួលបាន អត្ថប្រយោជន៍ទី៣ ទេ



ប្រសិនបើការរំលាយកិច្ចសន្យា កើតចេញពីឆន្ទៈនិយោជក ឬកំហុសកើតចេញពីនិយោជក នោះនិយោជិតទទួលបាន៖

- ប្រាក់ឈ្នួលចុងក្រោយ
- ប្រាក់ឈប់សម្រាកប្រចាំឆ្នាំដែលនៅសល់
- ប្រាក់បំណាច់បញ្ចប់កិច្ចសន្យា ស្មើនឹង ៥% នៃប្រាក់ឈ្នួលសរុបក្នុងរយៈពេលកិច្ចសន្យា និង
- សំណងជម្ងឺចិត្តដែលមានចំនួន យ៉ាងតិចស្មើនឹងប្រាក់ឈ្នួល ដែលកម្មករនិយោជិតទទួលបាន រហូតដល់ចប់កិច្ចសន្យា។

# ការបញ្ចប់កិច្ចសន្យា UDC

UDC ជាធម្មតាត្រូវបានបញ្ចប់ដោយផ្អែកលើកាលៈទេសៈដូចខាងក្រោម៖

- កិច្ចសន្យាត្រូវបានបញ្ចប់ដោយការយល់ព្រមពីភាគីទាំងពីរ
- កិច្ចសន្យាត្រូវបញ្ចប់ដោយការប្រព្រឹត្តខុសធ្ងន់ធ្ងរ ឬប្រធានសក្តិ
- កិច្ចសន្យាត្រូវបានបញ្ចប់ដោយផ្អែកលើឆន្ទៈឯកតោភាគីរបស់ភាគីណាមួយ

**មាត្រា ៧៥ នៃច្បាប់ស្តីពីការងារ៖** តម្រូវឱ្យនិយោជកផ្តល់ការជូនដំណឹងជាមុនដល់កម្មករនិយោជិតជាមុន លើកលែងតែការប្រព្រឹត្តខុសធ្ងន់ធ្ងរ ឬប្រធានសក្តិ

| រយៈពេលនៃការជូនដំណឹងជាមុន | រយៈពេលនៃការងារ |
|---|---|
| ៧ថ្ងៃ | តិចជាង ៦ ខែ |
| ១៥ ថ្ងៃ | ៦ ខែទៅ ២ ឆ្នាំ |
| ១ ខែ | លើសពី ២ ឆ្នាំទៅ ៥ ឆ្នាំ |
| ២ ខែ | លើសពី ៥ ឆ្នាំទៅ ១០ ឆ្នាំ |
| ៣ ខែ | ច្រើនជាង ១០ ឆ្នាំ។ |

# អត្ថប្រយោជន៍ទទួលបានក្រោយបញ្ចប់កិច្ចសន្យា UDC

**ក. ករណីកម្មករនិយោជិតលាឈប់ដោយឯកឯង និងមានការជូនដំណឹងត្រឹមត្រូវ៖**

- ទទួលបានប្រាក់ឈ្នួលចុងក្រោយ
- ប្រាក់ឈប់សម្រាកប្រចាំឆ្នាំដែលនៅសល់



**ខ. ករណីបញ្ចប់កិច្ចសន្យាដោយហេតុផលត្រឹមត្រូវរបស់និយោជក៖**

- ប្រាក់ឈ្នួលចុងក្រោយ
- ប្រាក់ឈប់សម្រាកប្រចាំឆ្នាំដែលនៅសល់
- ប្រាក់បំណាច់ទូទាត់ជួសការឲ្យដំណឹងមុន
- ប្រាក់បំណាច់អតីតភាពការងារ (មុន និង ក្រោយ ឆ្នាំ២០១៩)

**គ. ករណីរំលាយកិច្ចសន្យាដោយគ្មានហេតុផលត្រឹមត្រូវរបស់និយោជក៖**

- ប្រាក់ឈ្នួលចុងក្រោយ
- ប្រាក់ឈប់សម្រាកប្រចាំឆ្នាំដែលនៅសល់
- ប្រាក់បំណាច់ទូទាត់ជួសការឲ្យដំណឹងមុន
- ប្រាក់បំណាច់អតីតភាពការងារ (មុន និង ក្រោយ ឆ្នាំ២០១៩)
- សំណងជម្ងឺចិត្ត

សម្រាប់ព័ត៌មានបន្ថែម សូមស្កេន QR កូដ

រៀបចំដោយនិស្សិត៖ កញ្ញា ប៊ុន្នី សិរីវឌ្ឍនា, លោក ស៊ុយ សៀងហៃ, កញ្ញា សែល សូនីកា, លោក សុខ សុវណ្ណរតនៈ និង លោក ម៉ៅ វីរបុត្រ។

គម្រោងនេះគឺជាផ្នែកមួយនៃកម្មវិធី ELBBL-PLS ។ គម្រោងត្រូវបានបង្កើតឡើងក្នុងគោលបំណងអប់រំ និងចែករំលែកចំណេះដឹងតែប៉ុណ្ណោះ។ យើងស្វាគមន៍ក្នុងការទទួលបានមតិកែលម្អណាមួយតាមរយៈអ៊ីមែលខាងក្រោម។

Email: **bunnysereivathna@gmail.com**

គាំទ្រដោយ/ **Supported by:**

RAOUL WALLENBERG INSTITUTE
OF HUMAN RIGHTS AND HUMANITARIAN LAW